ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# កំណត់ហេតុ

## កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពី ការបង្ហាញរូបភាពមានលក្ខណៈ អាសអាភាស និងស្រើបស្រាលតាមប្រព័ន្ធផ្សព្វផ្សាយសង្គម

ថ្ងៃចន្ទ បួនរោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំ ត្រូវនឹងថ្ងៃទីម្ភៃប្រាំ ខែតុលា ឆ្នាំពីរពាន់ម្ភៃមួយ វេលាម៉ោងដប់បួន រសៀល នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានបើកកិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន ស្តីពីការបង្ហាញរូបភាពមានលក្ខណៈអាសអាភាស និងស្រើបស្រាលតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម កែវ សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ **ឯកឧត្តម ស្រី សួន** រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ **ឯកឧត្តម គឹម គុណាវឌ្ឍន៍** រដ្ឋលេខាធិការក្រសួងព័ត៌មាន និងជាប្រធានសមាគមទូរទស្សន៍ជាតិកម្ពុជា **លោកជំទាវ ហ៊ី នីរមុត្តា** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី **ឯកឧត្តម ប៊ុន ចន្នី** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម **លោក គឹម ហុងសាន** ព្រះរាជអាជ្ញារងអមសាលាដំបូលរាជធានីភ្នំពេញ **លោលជំទាវ ប៉ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ **លោក សន សេងហុក** ប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន រូប ស្រី រូប ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍ចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនាថ្ងៃនេះ ។ លោកជំទាវ មានប្រសាសន៍បន្ថែមថា នេះគឺជាលើកទី១ហើយដែលយើងជួបប្រជុំគ្នាជាលក្ខណៈអន្តរក្រសួង ស្តីពី ការបង្ហាញរូបភាពមានលក្ខណៈអាសអាភាស និងស្រើបស្រាលតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលនេះគឺជាបញ្ហាមួយដែលនាំឲ្យឈានទៅរកការជួញដូរផ្លូវភេទ និងអំពើជួញដូរមនុស្ស អ្វីដែលសំខាន់គឺបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស វប្បធម៌ ប្រពៃណីជាតិខ្មែរ សេចក្តីថ្លៃថ្នូរ និងបានជះឥទ្ធិពលដល់យុវវ័យ ដល់វិស័យអប់រំ ធ្វើឲ្យយុវជនមានការភ្លើតភ្លើន ដែលធ្វើឲ្យមានការលំបាកក្នុងការគ្រប់គ្រង ។ លោកជំទាវ បានលើកជាឧទាហរណ៍ថា ដូចជាករណី នារីឈ្មោះ **ឆោម ច័ន្ទ** ដែលបានបង្ហោះរូបភាពតុក្កតាដែលនាងបានទិញសម្រាប់ធ្វើជាប្តី ដែលនេះជារូបភាពមិនគួរគប្បីមកបង្ហាញនៅក្នុងបណ្តាញផ្សព្វផ្សាយសង្គមឡើយ ពាក់ព័ន្ធករណីនេះផងដែរក៏មានការលើកឡើងនូវមតិយោបល់រិះគន់ ក្នុងនោះ **លោកជំទាវ ហ៊ុន ស៊ីណាត** ក៏មានប្រតិកម្មខ្លាំងៗទៅលើករណី **នារីឈ្មោះ ឆោម ច័ន្ទ** ហើយ លោកជំទាវ បានមានប្រសាសន៍ស្នើទៅស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវចាត់វិធានការច្បាប់ទៅលើបុគ្គលណាដែលមានចេតនា បំផ្លាញកិត្តិយសនារីខ្មែរ សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណីជាតិខ្មែរ វិស័យអប់រំ ។ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍អរគុណ ចំពោះ លោកជំទាវ ហ៊ុន ស៊ីណាត ដែល